# ការសម្ភាសន៍របស់ លោកតា ហ័ង្ស សឿន

កៈ អ្នកសម្ភាសន៍ កុយ សុភី ខៈ អ្នកត្រូវបានគេសម្ភាសន៍ ហ័ង្ស សឿន

## **ការសង្ខេបប្រវត្តិរបស់លោកតា ហ័ង្ស សឿន**

លោកតា ហ័ង្ស សឿនមានអាយុ៦៩ឆ្នាំ កើតនៅក្នុងឆ្នាំម្សាញ់ ។ ការសម្ភាសនៅក្នុងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩។ មានម្ដាយឈ្មោះយ៉ម ហើយឪពុកឈ្មោះផាង មានបងប្អូន៨នាក់ សុតតែជាកូនប្រុស។ លោកតាយកប្រពន្ធជនជាតិផ្នង់ តែក្រោយមកលែងលះគ្នាដោយសារតែប្រពន្ធតាលេងល្បែង លោកតាមានប្រពន្ធសរុប៣នាក់ តែក្រោយមកបានបែកបាក់គ្នា ហើយលោកតាអត់មានកូននោះទេ។ ចំណែកឯងបងប្អូនរបស់លោកតាវិញ លោកតាបានប្រាប់ថា ពួកគាត់មានជីវៈភាពមានៗ ចឹងពួកគាត់អត់មានចង់រាប់អានលោកតាអីនោះទេហើយលោកតាក៏អត់ហ៊ានរាប់អានពួកគាត់ដែរ។ សព្វថ្ងៃនេះលោកតាបានរកស៊ីលក់ថ្នាំបុរាណខ្មែរដែលបានដឹងមកពីខ្មោចប្រាប់ផង! ព្រះអង្គប្រាប់ផង! ដែលថ្នាំទាំងនោះគឺរកបានមកនៅច្រើននៅលើភ្នំសំរាប់ព្យាលបាលជំងឺមួយចំនួនបានជាសះស្បើយ មិនតែប៉ុណ្ណោះ លោកតាមានបារមីកាន់ ដែលធ្វើអោយលោកតាអាចចេះទាយរាសី ជោគជាតារបស់មនុស្សបាន ដោយមានព្រះអង្គទាំង២ជាអ្នកជួយប្រាប់ ដែលព្រះអង្គមួយរូបបានមកពីលើភ្នំសន្ទុកជារូបឈើ នៅក្នុងមែកឈើ ឯមួយព្រះអង្គទៀត បានមកពីជ្រូកព្រៃជួយឈ្នួស! នៅក្នុងដីក៏លេចចេញរូបព្រះពុទ្ធរូបកែវមកនៅឯលើភ្នំឆាត នៅខេត្តរតនៈគីរី។

កៈ តាខ្ញុំជំរាបរលឹកតា! តើតាសព្វថ្ងៃនេះសុខសប្បាយដែរឬទេតា?
ខៈ បាទ! សុខសប្បាយនោះទេចៅ! បាទ!
កៈ ខ្ញុំឈ្មោះ កុយសុភី បានមកជួបតាគឺមានគោលបំណងសូមការអនុញ្ញាតសម្ភាសនៅឆ្នាំកុរ ឯកស័កពុទ្ធរាជ ២៥៦២ ខែពិសាខ ១៥កើត ត្រូវនឹងថ្ងៃសៅរ៍ទី១៨ ខែ ឧសភា ឆ្នាំ២០១៩ ។តើនាមត្រកូលរបស់តាមានឈ្មោះអ្វី?
ខៈ ត្រកូលរបស់តាឈ្មោះ ហ័ង្ស សឿន។
កៈ តើឈ្មោះហ្នឹងអ្នកណាជាអ្នកដាក់ឈ្មោះអោយ?
ខៈ ជីតារបស់ខ្ញុំ!
កៈ ជីតារបស់តានុងហេស?
ខៈ បាទ!
កៈ តើជីតារបស់តានុងគាត់ឈ្មោះអ្វី?
ខៈ ជីតារបស់ខ្ញុំនុង គាត់មានឈ្មោះថា ហ័ង្ស សឿនដែរ។បាទ!
កៈ អត់នោះទេ! ឈ្មោះតាហ័ង្ស!
ខៈ ឈ្មោះគាត់តាហ័ង្ស!
កៈ ចាស! ច្រលម!
ខៈ ខ្ញុំឈ្មោះ សឿន!
កៈ ចាស! តាឈ្មោះសឿន!
ខៈ បាទ! សឿននៅទី៨ នៅទី៨បាទ!។
កៈ នៅអង្គបានទី៨ហ៎?
ខៈ បាទ! នៅអង្គបានទី៨ បាទ!។
កៈ អូ! តើសព្វថ្ងៃតាមានឈ្មោះហៅក្រៅ១ទៀតដេស?
ខៈ អត់មានឈ្មោះអីទៀតនោះទេ មានតែប៉ុណ្ណឹងតែម្ដងចៅស្រី! មានតែប៉ុណ្ណឹង។

កៈ ចាស! តាមានអី! ថ្ងៃខែឆ្នាំកំណើត?
ខៈ ឆ្នាំកំណើតរបស់តាឆ្នាំម្សាញ់!
កៈ ហើយទៅមកដល់ឥឡូវតាអាយុប៉ុន្មាន?
ខៈអាយុបាន៦៩ហើយចៅស្រី!
កៈចាស!
ខៈ ៦៩!
កៈ អឺ! តាមានសញ្ជាតិអ្វី?
ខៈ សញ្ជាតិខ្មែរចៅស្រី!
កៈ កាន់សាសនា?
ខៈ បាទ! កាន់សាសនាខាងព្រះពុទ្ធហ្នឹង។
កៈ ចាស
ខៈ បាទ! ខាងព្រះពុទ្ធ។ បាទ!
កៈ តាមានមុខរបរអ្វីបច្ចុប្បន្នហ្នឹង អឺ! មុខរបរតាគឺមានលក់អី?
ខៈ តាមានថ្នាំក្រពះ ពោះវៀន ឬសដូងបាទ! រោគស្ត្រី ខាងក្តៅទ្រូង ក្តៅទ្វា
បើសិនជាមិនបាត់តាមិនយកលុយ ប្រាប់អោយចំតែម្តង ប្រាប់អោយចៅដឹង
បើសិនជាតាស្តោសក់ក្មេង អាយុ១៥ បើសិនជា២០នោះតាអត់ហ៊ានមើលនោះទេ
បើសិនជា១៥ចុះមកក្រោម តាហ៊ានធានាខុសត្រូវថ្នាំហ្នឹង! អោយតែថាស្តោសក់។
កៈ ចឹងតាបានព្យាបាលអ្នកដែលឈឺៗហ្នឹង
គឺដូចថាជាបានប៉ុន្មានភាគរយហើយបានតាហ៊ាន អះអាង?
ខៈ បាទ! ជាង១០% ហើយចៅ។
កៈ ទើបតែបាន១០%នោះទេហេស?
ខៈ បាទ! ទើបតែបាន១០%នោះទេ ។ បើសិនជានិយាយទៅ
ម៉ាខេត្តកំពង់ចាមចាប់ពីត្រឹមអាពីគេហៅថាភូមិអីគេនេះទៅឯណោះហ៎។
កៈ អូ!
ខៈ នៅពេលចំការ៣០ទៅឯនោះវិញ! ទៅតាមនទុងរហូតដល់ព្រែកកុយ! ។
កៈ ចឹងតាមើលនៅតាមដងទន្លេនុងហេស?
ខៈ បាទ! មើលតាមដងទន្លេមេគង្គយើងហ្នឹង ។បាទ! ដងទន្លេ !
កៈ នៅកងមាសហ្នឹងហេស?
ខៈ បាទ! ហ្នឹងហើយតាមទន្លេកងមាសហ្នឹង! តែនេះមិនទាន់បានទៅនោះទេ។
បាទ!
កៈ ចឹងតា ប្រកបមុខរបរលក់ថ្នាំឱសថបុរាណនុងចាប់ពីឆ្នាំណាមក?
ខៈ ២០១៩អូស! ២០១៧(លោកតាចង់និយាយថានៅឆ្នាំ២០១៧។)
កៈ ចឹងឆ្នាំ២០១៧!
ខៈ បាទ! ២០១៧!
កៈ ចឹងទើបតែបាន២ឆ្នាំហ្នឹងចឹង?
ខៈ ២ឆ្នាំឯណាចៅ មើលគិតមើល!
កៈ ចឹងតាតាំងពី២០១៧ ហើយឥឡូវមកដល់២០១៩ចឹងមិន២ឆ្នាំ?
ខៈ មិនមែននោះទេចៅ!
កៈ ចឹងបានប៉ុន្មានឆ្នាំហើយតា?
ខៈ តាធ្វើនុងតាំងពីខ្មោចប្រាប់នុង
តាំងពីជំនាន់មុនអាពតនុងទៀតណាចៅស្រី។
កៈ អូ! ចឹងយូរហើយ!
ខៈ បាទ! យូរហើយចៅស្រីបាទ!
កៈ តែថាតាអត់ចាំឆ្នាំនោះទេចឹង?
ខៈ អត់ចាំឆ្នាំនោះទេ!
កៈ ចឹងមិនមែនឆ្នាំហ្នឹងនោះទេចាស!
ខៈ អើ! វាភ្លេច!

ក៖ ចាស! មិនមែនឆ្នាំ២០១៧នោះទេ!
ខ៖បាទ!
ក៖ សង្ស័យ បើសិនជាមុនអាពតទៀតនោះគឺយូរហើយ!
ខ៖ បាទ! គឺយូរហើយចេះជួយសង្គ្រោះគេ។
ក៖ ចឹងថ្នាំនុងតាំងពីគេបានទំលាក់គ្រាប់បែប?
ខ៖ បាទ!នុងហើយ! កាលនុងមុនអុនតាក់នុងណា! ណាចៅ។
ក៖ អត់នោះទេ! អុនតាក់តាំងពីនៅឆ្នាំ៩២ និង៩៣នុងមែសនុងណា។ចាស!
ខ៖ នេះម៉ាជំនាន់នេះនុងណាចៅ! ...
ក៖ នៅរបបលន់ណល់?
ខ៖ នៅរបបលន់ណល់!ហ្នឹងហើយចៅបាទ។
ក៖ ជំនាន់គេទំលាក់គ្រាប់បែកយន្តហោះអីនុងហេសតា?
ខ៖ នុងហើយ!
ក៖ ចឹងតាអាយុប៉ុន្មានហើយ?
ខ៖ ខ្ញុំ២៧ហើយចៅ!
ក៖ កាលតាចេះផ្សំថ្នាំនុង២៧ហ៎!
ខ៖ បាទ!នុងហើយអាយុបាន២៧ឆ្នាំ។
ក៖ ពេលនុងតាមានប្រពន្ធហើយឬនៅ?
ខ៖ នៅនោះទេចៅ! អត់ទាន់ មាននោះទេ នៅកំលោះនោះទេ។
ក៖ អូ! ចឹងហ៎!
ខ៖ បាទ! នៅកំលោះនោះទេ! បាទ។
ក៖ ហើយដល់ចឹងពេលតា!មូលហេតុអ្វីបានតាចាប់ផ្តើម មុខរបរហ្នឹង?
ខ៖ មុខរបរហ្នឹង តាឃើញថាមនុស្សម្នាក់ៗវាចេះតែភរគេ
មួយថាថ្នាំហ្នឹងពូកែថ្នាំនោះពូកែ ហើយមកដល់ឥឡូវសាកថ្នាំតា
តាអត់មានយកលុយនោះទេ! តាជូន១កញ្ចប់អោយដល់ចៅឯង ហើយពិសារទៅ
បើសិនជា ជាហើយតាយកលុយ តែបើសិនជាអត់ជាតាអត់យកលុយ។
ក៖ អឺម! ចាស!
ខ៖ បាទ! ខ្ញុំប្រាប់ចឹង!
ក៖ ចឹងខ្ញុំទិញថ្នាំតា ៤កញ្ចប់ដែរ បើសិនជាផឹកទៅ បើសិនជាខ្ញុំជាហ្នឹង
ខ្ញុំជួយផ្សព្វផ្សាយតាបន្តទៀតណាតា!
ខ៖ បាទ!ៗនិយាយខ្ញុំប្រាប់ចឹងអោយចៅឯងដឹង កុំអោយថាអោយតា...
ក៖ ចឹងដូចថាតា កាលពីនៅកាលពីក្មេង តើតាបានចូលរៀនដេស?
ខ៖ រៀនបានបន្តិចបន្តួចដែរចៅ គឺថាបាននៅមើលគោ
បាននៅគ្វាគោអោយគេអត់បាន! បើថ្ងៃណាទំនេរទេ
បើសិនជា១ថ្ងៃៗនៅតែគ្វាគោអោយគេនុង។
ក៖ ហាក់! ចឹងតាកូនកំព្រានោះទេ?
ខ៖ បាទ! ខ្ញុំកូនកំព្រាតើខ្ញុំ ចឹងបានថាកូនកំព្រា...
ក៖ ចឹងពេលនុងតាអាយុប៉ុន្មានដែរតាពេលនុង?
ខ៖ ខ្ញុំអាយុ១៥ទៅ១៦នុង គឺនៅតែធ្វើខ្ញុំអោយគេនុង ដើរធ្វើ!...
ក៖ ចឹងដើរនៅជាមួយនឹងគេនុង?
ខ៖ ហ្នឹងហើយ! អោយតែបានរស់មួយពេលៗទៅ។
ក៖ គ្វាតែគោអោយគេទៅ?
ខ៖ បាទ! គ្វាតែគោនុងអោយគេទៅ ហើយទៅគេអោយ១ថ្ងៃ៥រៀល ១០រៀល
ក៏ខ្ញុំចេះតែធ្វើទៅ អោយតែបានរស់។បាទ!
ក៖ ហើយចឹងតើការគ្វាគោអោយគេនុង ពេលនុងបានច្រើនឬក៏តិចតា?
ខ៖ គោច្រើនណាចៅ មួយវ៉ូងៗណាចៅ។
ក៖ អូចឹងប្រហែលជា១០គោឡើង!

ខះ ២០គោ ៣០គោ ណាចៅ! ហើយដល់ចឹងទៅ
ពេលមកវិញទិញនំទិញអីអោយដល់យើងចឹងទៅ មានទឹកកកទឹកអីចឹងទៅណា។
កះ ចាស!
ខះ ហើយមានស្ករគ្រាប់អីចឹងទៅ ដល់ពេលមានកំលាំងនោះទៅទៀត។
កះ ចឹងតាអី! កូនកំព្រានុង កំព្រានៅអាយុប៉ុន្មានដែរតា?
ខះ នៅអាយុប្រហែលជា១៣ទៅ១៤នោះទេចៅ។
កះ ១៤?
ខះ បាទ១៤!
កះ ចឹងតើមូលហេតុអ្វីបានជាឪពុកតា...។
ខះ គាត់ខូចទៅយូរហើយអត់ស្គាល់ អត់ដឹងឃើញគាត់នោះផង!
កះ អូ! ចឹងគាត់ខូចតាំងពីតានៅពីតូចម៉េសហ៎?
ខះ ហ្នឹងហើយគាត់ខូចតាំងពីតានៅកាលពីតូចម៉េស!
កះ ហើយចុះម្តាយ?
ខះ បាទ! ម្តាយក៏គាត់ខូចដែរ។
កះចឹងតានៅតូចដែរ?
ខះ នៅតូចដែរ!ខ្ញុំអត់មានបានដឹងនោះទេ!
កះ អូ! ចឹងឪពុករបស់តាតើមានឈ្មោះអ្វី?
ខះ ម៉ែខ្ញុំ?
កះ ប៉ា?
ខះ ឈ្មោះ ...ម្តាយខ្ញុំណា! ឈ្មោះយាយយ៉ម ។
កះ យាយយ៉ម!
ខះ បាទ! ឪខ្ញុំឈ្មោះតាផាង! ហើយឪរបស់ឪពុកខ្ញុំឈ្មោះ តាហ័ង្សបាទ!
តែប៉ុណ្ណឹងបាទ។
កះ ចាសចឹងតើចំណែកឯតាវិញ តើតាមានបងប្អូនចំនួនប៉ុន្មាននាក់?
ខះ មាន៨នាក់! សុតតែប្រុស! បាទ! សុតតែប្រុស ប៉ុន្តែគេមានៗ
ខុសតែខ្ញុំនោះទេក្រជាងគេ។
កះ ហើយចឹងសូមតារាប់ឈ្មោះបងប្អូន?
ខះ ឈ្មោះផាន!
កះ ភេទប្រុសហេស?
ខះ ស្រី!
កះ ភេទស្រី?
ខះ បាទ!ភេទស្រីផាន ដល់ពេលបងខ្ញុំ១នាក់ទៀតឈ្មោះបងកុយ។
កះ ភេទប្រុស?
ខះ បាទ! ប្រុសដែរ! រួចហើយទៅគឺស្រី២ៗណា បុប្ផាប៉ុន្តែងាប់ហើយណា ។
កះ ចាស!
ខះ ម៉ាជំនាន់នុងងាប់ហើយ! កុយខ្ញុំក៏ងាប់ អាមឿនក៏ងាប់
រួចទៅបានបងខ្ញុំឈ្មោះផាត ស្តាប់បានឬនៅ? ដែលមកបន្ទាប់ខ្ញុំនេះណា។
កះ ចាស!
ខះ ដល់ពេលរួចទៅបានផាតស្រឿន ដល់ពេលស្រឿនហ្នឹងហើយទៅ បានស្រុន
ស៊ុនរួចចឹងទៅ បានឃ្លោក បាទ! បាន៨នាក់។
កះ ហ៊ឹម...។
ខះ បាទ! ៨នាក់បងប្អូនប៉ុន្តែគេសុតតែមានៗ។
កះ ឥឡូវនេះនៅរស់ប៉ុន្មាន?
ខះ នៅរស់សព្វថ្ងៃគឺនៅ៥។
កះ ចឹងស្លាប់អស់៣ហើយ?
ខះ បាទ! ស្លាប់អស់៣ហើយ ខ្ញុំប្រាប់គ្រង់។
កះ មើលតានៅទីប៉ុន្មាន?

ខៈ ខ្ញុំទី៤!
កៈ តាទី៤ហេស?
ខៈ បាទ! គឺទី៤
ក៏ប៉ុន្តែបងប្អូនរបស់ខ្ញុំគេសុតតែមានៗចឹងគេមិនសូវជារាប់នោះទេ
គេរាប់តែអ្នកមានៗនោះទេចៅ! នេះតាប្រាប់ត្រង់ៗ។
កៈ ចាស!
ខៈ បាទ!
កៈ ដល់ពេលតានៅអាយុប៉ុន្មានបានជាតាមានគ្រួសារ?
ខៈ ខ្ញុំម៉ា៣៧!
កៈ ចឹងអាយុ៣៧មានគ្រួសារ?
ខៈ បាទ!
កៈ ចឹងប្រពន្ធរបស់តាមានឈ្មោះអ្វី?
ខៈ ប្រពន្ធរបស់ខ្ញុំនុងឈ្មោះ កាព្រៀន!
កៈ ចាសគាត់ជាជនជាតិ?
ខៈ ជនជាតិ...
កៈ ជនជាតិអីគេដែរ ខាងផ្នង?
ខៈ ខាងផ្នង!
កៈ ជនជាតិ ផ្លួយ ឬក៏សំរ៉ែ?
ខៈ ទេ! អត់នោះទេ គាត់ជនជាតិផ្នង!
កៈ ចឹងផ្នងទេហ៎?
ខៈ បាទ! ផ្នង ពួកអ្នកដែលពាក់ក្រវិលនុងណា។
កៈ អូ!
ខៈ ហាទ! ពួកអាប្រហោងត្រចៀងដាក់ទឹកចឹងណា រួចទៅដាក់ទឹកនៅក្នុងនុង
ក៏ប៉ុន្តែខ្ញុំសព្វថ្ងៃ ខុសវាលេងល្បែងបន្តិច ខ្ញុំក៏ឈប់យកទៅ។
កៈ អូ !...គាត់លេងល្បែងហ៎?
ខៈ បាទ! លេងល្បែងចៅអើយ!
កៈ ចឹងតាយកជនជាតិហ្នឹងនៅក្នុងខេត្តណាតា?
ខៈ នៅខេត្តឯខាងរតនៈគីរី។
ㅇ:គីរី។
កៈ ចឹងនៅខាងរតនៈគីរីហ៎!?
ខៈ បាទ! នៅខាងរតនៈគីរី!
កៈ អូ...បានទៅយក! ចុះតាម៉េចបានជាតាចង់ធ្វើដំណើរទៅខេត្តនុងតា?
ខៈ ខ្ញុំបានចុះទៅខេត្តនុងចៅ!
កៈ ដាំដំឡូងអោយគេហ៎?
ខៈ បាទ! ដាំដំឡូង ធ្វើដំឡូងអោយគេនោះទេ ខ្ញុំអត់មានធ្វើអីនោះទេ
ទៅនុងទៅធ្វើខ្ញុំគេនោះទេ(អ្នកបំរើ! អ្នកធ្វើការអោយគេ។)
កៈ ចាស!
ខៈ ហ្នឹងហើយ!
កៈ ចឹងបានជួបប្រពន្ធតានុងទៅ?
ខៈ បាទ!
កៈ ហើយទៅយកគាត់...
ខៈ បាទ! បានតែ៥ឆ្នាំខ្ញុំលែងវិញ។
កៈ មូលហេតុអ្វី គាត់លេងល្បែងហ៎?
ខៈ បាទ! គាត់លេងល្បែង ចឹងខ្ញុំអត់យក! គេនុងសស្អុស គេនុងហ៎។
កៈ ហឺម!
ខៈ បាទ! រូបរាងស្អាតក៏ប៉ុន្តែទាល់លេងល្បែង ចឹងខ្ញុំអត់យកនោះទេ។
កៈ ចាសចឹងបានតាធ្វើដំណើរមកស្រុកកំណើតវិញ?

ខះ បាទ!
ខ្ញុំបានរស់នៅឡើងរាប់ឆ្នាំនៅឯនុងហើយបានមកខ្ញុំចេះរកថ្នាំបានច្រើនមកបាន៤បេ បាន៥បេ អីចឹងទៅ ហើយក៏យកមកទុកនៅផ្ទះ ឯបងខ្ញុំឯនេះ
ចឹងខ្ញុំប្រាប់តាមត្រង់បាទ។
កះ ចាស! ដល់ពេលនុងទៅបានតាឈប់នៅឯនុងចឹងទៅ
ហើយបានតាមកនៅឯស្រុកកំណើតនេះ?
ខះ បាទ! ស្រុកកំណើតទៅមកៗណាចៅ។
កះ ចឹងហេស?
ខះ ទៅមកៗ ណាចៅ។
កះ តែរកថ្នាំនុងហេស?
ខះ បាទ! ទៅរកនៅឯនុងខ្លាំង ហើយវាពូកែលជាថ្នាំនៅឯខាងនោះ។
កះ ចឹងហេស?
ខះ បាទ!ព្រោះអីថ្នាំ ខ្មោចប្រាប់ផង ខ្ញុំបានផ្សំលិច ផ្សំកើតទៀតទៅ។
កះ ចាស!
ខះ បាទ! ដល់ពេលផ្សំទៅវាជាគេទៅ! មើលគេទៅឃើញថារោគនុងវាត្រូវជាណា ខ្ញុំដាក់តែដ៏ដែរ ថ្នាំនុងទៅដ៏ដែរទៅ បាទ។បើសិនជាថាលើសឈាមនុង មានថ្នាំលើសឈាមនោះផ្សេង ហើយមានអាសំពាធឈាមនុងមើលតាមហ្នឹងទៅ បើសិនជាថាបើសិនជាសញ្ញាវា! សំពាធឈាមមានសញ្ញារបស់វា B, C មួយ ពីរ បើសិនជាមិនជានោះតាអត់មានយកលុយនោះទេ!
អោយថ្នាំនុងយកទៅពិសារទៅ បាទរួចបើសិនជារោគថ្លើមឡើងដល់ B ទៅC បីនោះតាអត់មើលនោះទេ កុំអោយ! បើសិនជាថាត្រូវហើយបានតានុង យក១០០ តែប៉ុណ្ណឹងនោះទេ ចឹងអត់មានយកច្រើននោះទេ តែ១០០នោះទេ ។
កះ ហើយចឹងបើសិនជាឬសដូងវិល?
ខះ បើសិនជាឬសដូងវិល !...
កះ ស្មោសក់នុងយ៉ាងម៉េចដែរ?
ខះ បើសិនជា ជាមិនបាត់នៅតែស្មោសក់ទៀតតាអត់យកនោះទេ
ចេះតែបញ្ជូនថ្នាំអោយទៅទៀត។
កះ អូ!...
ខះ ត្រឹមតែ២០កញ្ចប់នោះទេចៅ!
កះ ចាស!
ខះ បាទ! បើសិនជាមិនបាត់នោះគឺតាអត់មានយកលុយនោះទេ ព្រោះអីខ្លាំង ។
កះ ចាស!
ខះ នេះតាប្រាប់ថាចឹង!
កះ នេះចំណែកឬសដូងស្មោសក់?
ខះ បាទ! ឬសដូងស្មោសក់! រួចបើថាឬសដូងវិល អាហ្នឹងដឹងតែបាត់ហើយចៅ តែ២កញ្ចប់នោះទេ។
កះ ចឹងចេះតែឧស្សាហ៍វិលមុខនុងហេសចៅ?
ខះ ហ្នឹងហើយវិល!រហត់រហៃ វិលមុខ ដើបឡើងវិល ដើបឡើងវិល
ទៅដល់ពេលតាដាក់តែ២កញ្ចប់នោះទេចៅ
តាមានដាក់ជាកញ្ចប់ឡើងតែវែងនេះនោះទេ ដាក់ត្រឹមត្រូវ។
កះ ចាស!
ខះ មានផ្លាក! នេះតាប្រាប់ចៅឯងអោយបានតាមត្រង់ចឹង!
កះ រួចចុះចំណែកអីគេដែលគេហៅថាឬសដូងបាទអីនោះ?
ខះ ឬដូងបាទនុង អាហ្នឹង៨កញ្ចប់ ហើយអានេះបើសិនជាមិនជាសងលុយវិញ អត់ចង់បាននោះទេ។
កះ ចាស!

ខ៖ ជូនថ្នាំអោយពិសារទៀត ថែមទៀតហ្នឹងប្រាប់ចឹង
តាអត់មានចង់បាននោះទេរឿងចឹង
ថ្នាំតាមានបានចង់ចេះបានរបស់គេនោះទេចៅ! ។
ក៖ ចាស!
ខ៖ មានតែ១សារនុង! ហើយចឹងចុះ! ដូចជាថ្នាំចុកជើង
ចុកដៃនុងដឹងតែបាត់ហើយ ប៉ុន្តែអោយតម
បើសិនជាមិនតមនោះអត់មានបាត់នោះទេចៅ។
ក៖ចាស!
ខ៖ បើសិនជាមិនតមនោះមិនបាត់នោះទេ។
ក៖ ចាស!
ខ៖ ចឹងតមត្រពាំង ពងទា ហើយនិងខ្លាញ់តែ៣មុខហ្នឹងនោះទេ។
ក៖ អាហ្នឹងចំណែកខាងក្រពះហើយនិងពោះវៀនហាំ?
ខ៖ បាទ!ក្រពះពោះវៀនតែប៉ុណ្ណឹងនោះទេ! អោយតមតែ៣មុខហ្នឹង
ហើយបើសិនជាអីៗផ្សេងមិនបាច់នោះទេ។ បាទ!
ក៖ ហើយចុះចំណែកអ្នកផ្សេងដែរ ផ្នែករោគស្ត្រីវិញ?
ខ៖ បើសិនជារោគស្ត្រីវិញ ដូចថាទ្វារមួស ហើយក្តៅទ្រូង
ក្តៅភ្នែកក្រហល់ក្រហាយភ្នែក ស្រវាំងៗ មើលសៀវភៅ មើលអីមិនឃើញចឹង
ដាក់អស់តែ២កញ្ចប់នោះទេចៅ។
ក៖ ចឹងជាហើយ?
ខ៖ បាទ! ដាក់អស់តែ២កញ្ចប់នោះជាហើយចៅ ជាហើយ តែ២កញ្ចប់នោះទេ។
ក៖ ចាស!
ខ៖ ប៉ុន្តែអាហ្នឹងថ្លៃ! គាលក់ម៉ាកញ្ចប់៥០០០
តែបើសិនជាចៅឯងទិញអាណិតចៅឯងនោះទេបាន៣០០០នុងហាំ។
ក៖ ចឹង!
ខ៖ បាទ!
ក៖ ចាសៗ នុងហើយអរគុណ!
ខ៖ ហ្នឹងហើយ!
ក៖ ចាសអរគុណតាច្រើន!
ខ៖ តាសង្គ្រោះមនុស្សលោកច្រើនឡើងសន្ធឹកណា
បើសិនជាចៅឯងមិនជឿនេះចំការឪឡឹក ពាមក្នុង អីនោះសួរគេទៅ
បើសិនជាចៅឯងមិនជឿ តាមកកន្លែងហ្នឹងដាច់ គេរកតែថ្នាំហ្នឹងនោះទេចៅ។
ក៖ ចាស!
ខ៖ បាទ!ចិនៗគេរកទិញតែថ្នាំហ្នឹង។ នេះគ្រាន់តែតាជួយប្រាប់ចឹង!
ក៖ ឥឡូវតា!អឺ...។
ខ៖ នេះតាប្រាប់ដល់ចៅឯងអោយបានដឹងថាកុំអោយចៅឯងនេះអត់បានដឹង
តាមកលក់នេះបាន២ដងរួចទៅហើយណាចៅ។
ក៖ ចឹងហាំបានមកលក់នៅក្នុងភូមិនេះទើបតែ...។
ខ៖ បាទ! មកលក់នៅឯខាងផ្សារហ្នឹងបាន២ដងហើយទើបតែ
នេះចៅឯបានមាននិស្ស័យជាមួយនឹងតា ហើយចឹងតាប្រាប់ចឹងបាទ។
ក៖ ឥឡូវតា អឺ!
ចាប់ពីដូចថាឈប់ពីរតនៈគីរីដូចថាតាលែងទៅរតនៈគីរីនៅមកដល់ពេលឥឡូវហ្នឹង?
ខ៖ លែងទៅហើយចៅ! លែងទៅហើយ!
ក៖ ចាស!
ខ៖ តាមកនៅឯខាងស្រុករបស់តាវិញ។
ក៖ ចឹងតាយកថ្នាំមកលក់នៅរាល់តែថ្ងៃហ្នឹង តើតាទៅរកពីណាមកវិញ?

ខៈ គឺតាបានទៅរកច្រើនជាងគេគឺនៅឯភ្នំគូលេន និងភ្នំសន្ទុកនុងតែម្តង
តែ២មុខហ្នឹងនោះទេ តាបានជិះឡានពីនេះទៅអស់ម្តង២០០០០ ទៅ៣០០០០
ហើយមកដល់វិញ អស់ម្តង៥០០០០ ។ តាដាក់ម្តង៥បេ
ហើយបានម្តងបាន៥លានចឹងទៅចៅ។
កៈ ចាស!
ខៈ បាទ!ហ្នឹងថ្នាំវាមានមុខត្រូវនោះទេចៅ ថាថ្នាំនេះវាបានត្រូវមុខជំងឺអី ។
កៈ ចាស!
ខៈ អឺ!ហើយថាតើថ្នាំនេះវាត្រូវនឹងមុខអី?
កៈ ចាស!
ខៈ បើសិនជាឬសដូងបាទនោះគឺដាក់ថ្នាំឬសដូងបាទ គឺថាបានមួយមុខវា
ដាក់នៅ១បេផ្សេងចឹងទៅ។
កៈ ចាសៗ
ខៈ ដូចថារោគស្ត្រីនោះដាក់១បេ វានោះផ្សេងទៅបាទ!
អត់មានបានចេះដាក់នៅកន្លែងជាមួយនឹងថ្នាំ គ្រពះ និងពោះវៀនអីនោះទេ
ហើយចឹងអាថ្នាំសរសៃនោះគឺដាក់ដោយលែកពីគ្នាចឹងទៅ បាទ! អាហ្នឹងចៅ
តាសូមប្រាប់ថាចឹង។
កៈ ចាស
ខៈ បាទ!រួចទៅស្រុកកំណើតរបស់តានៅអង្គបាននេះប្រាប់ចៅអោយដឹង។
បងប្អូនរបស់ខ្ញុំ នៅសព្វថ្ងៃហ្នឹងណា ។
កៈ ចាស!
ខៈ ស្រ៊ុនមុំ!
កៈ ចាស! ស្រ៊ុនមុំហេស?
ខៈ បាទ! ស្រ៊ុនមុំ ទី៨ ចៅ!(គាត់ចង់ថាកន្លែងនុងឈ្មោះទី៨)
កៈ ទី៨!
ខៈហ្នឹងបងប្អូនខ្ញុំ! ផាត់ យ៉ុង! នៅតែ២នាក់ហ្នឹងនោះទេណា។
កៈ ចឹងតានៅអង្គបានទី៨?
ខៈ បាទ! នៅអង្គបានទី៨!
កៈ ចឹងតានៅឯនុងទៅជាមួយនឹងប្អូន?
ខៈ បាទ! នៅជាមួយនឹងផ្ទះប្អូនសព្វថ្ងៃហ្នឹង ព្រោះអីខ្ញុំអត់មានផ្ទះនៅនោះទេ។
កៈ ចាស!
ខៈ បាទ! មានតែនៅឯណោះ នោះទេ! គឺមានតែនៅឯខាង...
កៈ នៅឯខាងណា?
ខៈ នៅឯខាងកំពង់ធំ!
កៈ ចាស!
ខៈ ខ្ញុំបានទៅយកថ្នាំនៅកំពង់ ធំ ព្រោះអីខ្ញុំខស្បាហ៍ទៅកន្លែងនុងយកថ្នាំណាស់
តាំងពីខាងស្រុកកន្លែងដាំថ្នាំនុងណា។
កៈ ចាស!
ខៈ ដល់ពេលហើយបានគ្រាប់បានច្រើនបានតាជិះឡានក្រុងនុងមក!
តើមានស្គាល់ឡានតាឡុងដេស?
កៈ ស្គាល់!
ខៈ អើ! ឡានតាឡុងនេះសួរតែគាត់ទៅ ខ្ញុំជិះតែឡានគាត់នោះទេ។
កៈ អូ!...
ខៈ សំរាប់មកវិញ ម្តងៗបាន៣បេ ៥បេ។
កៈ រកតែតាឯម្នាក់ឯងនោះទេ?
ខៈខ្ញុំរកតែម្នាក់ឯង កាប់ជញ្ជាំ គាស់ ដាក់ហាល ដោយខ្លួនឯង ប្រពន្ធ ដើយ
គឺប្រពន្ធដើយ ឃើញថ្នាំដើយ! អត់មានមកជួយកាប់នោះទេ តែខ្ញុំនោះទេ
ដែលយកកាំបិតមកកាំ១ មានពូថៅ១ ដល់ពេលថាបានមកចឹង

មានអំពូលម៉ែត្រ១ ខ្ញុំកាប់នៅពេលយប់ទៅ កុំអោយផ្លង់គេ
ចឹងហើយខ្ញុំក៏បានកាប់វាដាក់នៅក្នុង(15:45) ។
ក៖ អូ!...
ខ៖ បាទ! ដល់ពេលម៉ោង១២បានខ្ញុំដេក។
ក៖ អឺម!
ខ៖ បាទព្រឹកឡើងខ្ញុំកាប់ចាក់ហាល ដល់ពេលព្រលឹមឡើងខ្ញុំទៅកាប់ទៀត។ បាទ!
ប្រាប់ដល់ចៅឯងចឹងអោយដឹង!
ក៖ ចាសចឹងតាមានប្រពន្ធ១នាក់ទៀតនៅឯខាង?
ខ៖ នៅឯនុង!
ក៖ ចាស!ចឹងប្រពន្ធនៅខាងក្រោយនុង តាយក...
ខ៖ ទើបតែបានយកប៉ុន្មាននេះនោះទេចៅ!
ក៖ ចឹងស្រុកកំណើតរបស់គាត់នៅខាងកំពង់ធំនេះ?
ខ៖ បាទ!
ក៖ ប្រពន្ធទី២នេះហ្នឹងហេស?
ខ៖ បាទ! ប្រពន្ធទី២!
ក៖ ចឹងប្រពន្ធទី២នុងមានឈ្មោះអ្វីដែរតា?
ខ៖ ឈ្មោះ សៅអឿន!
ក៖ ចាស!
ខ៖ បាទ!
ក៖ ហើយចឹងតើពេលនុងបានជួបគ្នាយ៉ាងម៉េចដែរបានតាយកប្រពន្ធទី២ទៀត?
ខ៖ ឈឺច្រើនពេក!
ក៖ យាយនុងហេស?
ខ៖ បាទ! យាយនុងគាត់ឈឺច្រើនពេក ទៅរកគ្រូនោះវាអត់ជា! រកគ្រូនុងវាអត់ជា
ទៅ១ទៀតវាមិនជា បានព្រះអង្គខ្ញុំហ្នឹង ខ្ញុំប្រក់ព្រំអោយណា! ចឹងបានធូ
ដល់ពេលបានធូ ចឹងផឹកទៅ! ផឹកអស់តែ២ទៅ៣ត្រឡោក បានហើយបាទ!
កុំផឹកយកច្រើនពេក។
ក៖ ចឹងផឹក៣យកទឹក១!
ខ៖ បាទ! ហ្នឹងហើយ!៣ត្រឡោយក១ត្រឡោ ហើយដល់ពេលផឹកទៅធូ! តាមរកខ្ញុំ
រកលេខខ្ញុំនុងផ្ញើ ជាប្តីតែម្តង។
ក៖ ចឹងហ៎!
ខ៖ បាទ!
ក៖ ចុះចំណែកគាត់នុង?
ខ៖ ម៉េម៉ាយនោះទេ!
ក៖ ម៉េម៉ាយដែរ! ចឹងគាត់មានអាយុប៉ុន្មាន?
ខ៖ គាត់ម៉េម៉ាយនុងអាយុបាន៤៧។
ក៖ ៤៧ហ៎!
ខ៖ បាទ!៤៧! បាទ!
ក៖ អឺម!
ហើយមកដល់ពេលឥឡូវហ្នឹងតាបានយកគាត់មកនៅឯខាងស្រុកកំណើតរបស់
តាវិញហើយ?
ខ៖ បាទ! មករស់នៅឯទួលសន្ទាក់!
ក៖ ចឹងនៅទួលសន្ទាក់!
ខ៖ បាទ!នៅទួលសន្ទាក់ហ្នឹងបាទ។
ក៖ ចឹងទិញដីអីផ្ទះនៅឯហ្នឹង?
ខ៖ អត់នោះទេ! ផ្ទះរបស់គេតែម្តង ផ្ទះតូចនោះទេ ផ្ទះរបស់វា។
ក៖ ចឹងផ្ទះគាត់!
ខ៖ បាទ! ផ្ទះវា!

កៈ ចឹងមិនមែននៅខាងកំពង់ធំនោះទេ?
ខៈ អត់នោះទេ ! បើសិនជានៅខាងកំពង់ធំនោះគឺមាន១។
កៈ ចឹងមាន១ដែរ!
ខៈ បាទ! នៅឯនុងមាន១ហើយនុងគឺគេបាននៅខាងអូថ្នាំ!
កៈ អូ!... ចឹងបានជួយរកថ្នាំតា?
ខៈ បាទ! ហ្នឹងហើយ!
កៈ ហឹមចឹង!
ខៈ គ្រាន់តែថាបានកាប់អីរួច វាដេកធ្វើមិនដឹងដេកចង់អង្រឹងចឹងទៅ
គេមើលស្អីគេ អាំហ្វេសប៊ុកអីចឹងទៅ។
កៈ ចឹងហ៎!
ខៈ អឺ! គេអត់មានមកជួយចិញ្ចាំ ដល់ខ្ញុំនោះទេ។
កៈ ចឹងនៅកំពង់ធំនោះ១ដែរ?
ខៈ បាទ!១
កៈ ចឹងតាមានប្រពន្ធ៣ហ៎?
ខៈ ៣ តែមុននុងងាប់១ហើយនៅ២ ស្តាប់បានដែរឬទេចៅ?
កៈ ចឹងមកដល់ពេលឥឡូវហ្នឹងនៅ២?
ខៈ បាទ! នៅ២!
កៈ រួចនៅកំពង់ធំនៅជួបយ៉ាងម៉េចដែរបានជាគាយក?
ខៈ នុងកាលនុង ជួបដោយចៃដន្យនុងហ៎ ដល់នុងលក់ថ្នាំអាថ្នាំជក់ណាចៅ!
កៈ ចាសថ្នាំជក់!
ខៈ ដល់ពេលរួចចឹងទៅខ្ញុំជិះកង់ទៅ!
កៈ ថ្នាំខ្មែរយើងហ្នឹង?
ខៈ បាទ! ថ្នាំខ្មែរយើង ដល់ពេលខ្ញុំជិះកង់ទៅ ។
កៈ ចាស!
ខៈ សុំសំណាក់ផ្ទះគេដេកអីចឹងណា!
កៈ ចាស!
ខៈ ហើយចឹងគាត់បានជួយលក់ថ្នាំខ្ញុំអីចឹងទៅណាបាទ!
ហើយក៏បានជួយដើរលក់ចឹងទៅ
ក៏បានអស់ឡើងរលីងចិញ្ចឹងទៅចៅ។រួចទៅស្រាប់តែខ្ញុំនេះ
ខ្ញុំបានចង់អង្រឹងនៅក្រោមដើមអំបិលមួយដើម ហើយមានរបង់គេចឹងណា
ខ្ញុំចង់អង្រឹងនៅដេកនុងចឹង ហើយចេះតែមកថា រួចពូនោះថា!ៈ គាឯង!
អូប្អូនឯងមានប្អូននៅ? ចេះតែមកសួរដល់ខ្ញុំចឹងណា! ខ្ញុំថាអត់ទាន់មានផង
ខ្ញុំអត់មានទាន់មានប្រពន្ធផង!
ដល់ពេលហើយខ្ញុំបានមកដើរលក់ថ្នាំអោយតែបានលុយទៅ គឺខ្ញុំអាយកប្រពន្ធ!
ហើយចឹងគាត់ថា៖ ចង់យកនាងនេះតែម្តងទៅចឹង! ព្រោះអីបងប្អូនគេនោះ!។
កៈ ចាស!
ខៈ ថាយកនាងនុងទៅ នាងនុងថាសប៉ុនចៅឯងហ្នឹង សប៉ុនចៅឯនុង!
កៈ ចាស!
ខៈ ហើយទៅក៏ខ្ញុំពេលនុងអើ! លុយបានហើយនោះចឹងមានអី។
កៈ ចាស!
ខៈ លក់ថ្នាំបានច្រើនដែលលុយ១បេនុង៣ជានុងមិនតិចឯណា។
កៈចាស!
ខៈ ដល់ចឹងទៅ ក៏គេរៀបម៉ាព្រឹកអោយទៅ។
កៈ អូ...
ខៈបាទ! រៀបបាន១ព្រឹកអោយទៅ។
កៈ រៀបបាន១ព្រឹកចឹងកាលនុង
តាបានជូនជំនួនអោយខាងស្រីបានប៉ុន្មានដែរ?

ខៈ បានជ្រូក១ចំហៀង ហើយលុយបាន៥០ម៉ឺន។
កៈ អូ...។
ខៈ កាលនុងគេស៊ីក្រាលកន្ទេលនោះទេចៅ អត់មានអីនោះទេ ក្រាលកន្ទេលត្នោតប្រាប់ដល់ចៅចេះ។
កៈ ចាស!ចឹងនៅ...ចុះប្រពន្ធដែលតាបានរៀបនៅកន្ទេលនុង តើគាត់អាយុប៉ុន្មានដែរ?
ខៈ គាត់អាយុ២៧!
កៈ តើគាត់អី!           ឈ្មោះអ្វី?
ខៈ ឈ្មោះយាយលន់!
កៈ យាយលន់!
ខៈ ឪពុករបស់គាត់ ឈ្មោះតាបាន យាយលន់ហ្នឹងហើយ! ហើយអត់មានកូនអត់មានចៅនោះទេ។
កៈ អត់មានកូននោះទេ!
ខៈ អត់កូនមកដល់ពេលខ្ញុំនេះក៏អត់កូនដែរ កំព្រាកូនអើ!
កៈ ចាស!
ខៈ ព្រោះអីវាសុតតែចាស់ៗដែរទៅណា វាអស់រដូវនុងទៅអត់មាន អើគ្រាន់យកបានជាគ្នាទៅបានហើយ។
កៈ ចាស!
ខៈ បាទ! គ្រាន់តែបានជាគ្នាទៅធ្វើយ៉ាងម៉េចនោះទេ បើសិនជាចឹង។
កៈ រួចចុះប្រពន្ធតានៅខាងកំពង់ធំនោះយ៉ាងម៉េចដែរ មកលេង?
ខៈ មកលេងដែរតើចៅ!
កៈ មកលេងដែរហ៎!
ខៈ បាទមកលេងប្រហែលជាបាន៣ដងហើយ។
កៈ ចឹងហ៎!
ខៈ បាទ! មកលេងបងប្អូននុងណាចឹងបានមកលេងបាន៣ដងហើយមកលេងនៅខាងបងប្អូននៅឯអង្គបាននេះ។
កៈ ចាស!
ខៈ មកលេងជិះឡានតាហុងហ្នឹងដែរនុង ហើយនេះមកលេងបាត់រាងយូរហើយខ្ញុំមកឡើងបាន១០ថ្ងៃទាំងថ្ងៃនេះហើយនេះ។
កៈ ចាស!
ខៈ បាទ!មក១០ថ្ងៃហើយ បាននៅសល់ថ្ងៃពីដៃតែប៉ុណ្ណឹងនោះទេ។បាទ!លក់អស់ហើយថ្នាំនោះ នៅសល់តែថ្ងៃក្រពះនិងថ្នាំសរសៃរចាំខ្ញុំ យកអោយ!ៗម៉ានុង អោយ១កញ្ចប់ណា។
កៈ ចាស!
ខៈ ថ្នាំសរសៃរណាបាទអោយ១កញ្ចប់នៅថ្ងៃស្អែកនេះខ្ញុំយកមកហ្នឹង។
កៈ ចាសចឹងតាដល់ពេលចឹង កាលពីអតិតកាលកាលពីពេលតានៅពីក្មេងតើតាមានបានចូលរៀនដែរឬទេ?
ខៈ រៀនបានតិចណាស់ចៅ រៀនបានត្រឹមថ្នាក់ទី៦នោះទេ កាលរៀននុងមិនសូវជាបានចេះដឹងអីប៉ុន្មានផង គិតតែមើលគោអោយគេបាទ ចេះតែធ្វើការអោយគេទៅ ជាកម្មករចឹងធ្វើបាន១ថ្ងៃទៅបានស៊ី១ថ្ងៃចឹងទៅណាបាទ។មានបងប្អូនគេមានៗចឹងហើយខ្ញុំអត់មានហ៊ានទៅនោះទេបាទ! ដល់តែពីខ្ញុំចេះរក ដំរិះមកដោយខ្លួនរបស់ខ្ញុំទៅ មើលទៅមិនកើតចឹងហើយខ្ញុំក៏បានបកទៅស្រុកនៅខាងលើនោះវិញបាទ ដើរទៅរកថ្នាំវិញបាទ។

កៈ ចឹងតាពេលដែលតានៅក្នុងរបបប៉ុលពត
តើតាមានជីវៈភាពយ៉ាងម៉េចដែរចូលតារៀបរាប់?
ខៈ ហ្នឹងកាលពីម៉ាជំនាន់ប៉ុលពតនុង ខ្ញុំនិយាយត្រង់ខ្ញុំមុនដំបូង ខ្ញុំកាប់ដី
ខ្ញុំលើកដី នៅក្នុង១ថ្ងៃហ្នឹង បើសិនជាមិនបាន២ម៉ែត្រ ថៃសណា ហើយទទឹងថែស
១ម៉ែត្រស្លាប់បានដេសចៅស្រី?
បើសិនជាលើកមិនរួចនោះទេគេមិនអោយស៊ីនោះទេ នៅក្នុងរបរបនុង?
កៈ ចឹងបណ្តោយ២ម៉ែត្រហើយទទឹង១ម៉ែត្រ?
ខៈ បាទ! រួចហើយបណ្តោយចុះទៅក្រោមទៀតបាន១ម៉ែត្រទៀត។បាទ!
កាប់នុងគេធ្វើប្រឡាយណា!
កៈ ចឹងហ៎ ចឹងពេលនុងតាជីនុងរែកអីរួចដែស?
ខៈ រែករួចចៅ! បាទនៅកំលាំងនៅផិលនៅកាលជំនាន់នុង
អត់ទាន់មាននេះនោះទេចៅស្រី ។
កៈ ចាស!ដល់ពេលតារែកប្រឡាយអីហើយទៅ
តើតាបានទៅធ្វើការងារអីគេទៀតបន្តទៀត?
ខៈ រែកប្រឡាយរួចទៅ តាទៅនៅចំការកៅស៊ូចៅ ។
កៈ នៅចំការកៅស៊ូនៅខាងណា?
ខៈ ទៅចាក់ជ័រ! នៅចំការកៅស៊ូនៅចំការអណ្តូងយើងហ្នឹងណាចៅ
ម៉ាជំនាន់ប៉ុលពតនុងគេអោយទៅធ្វើការនៅចំការកៅស៊ូ
កាលនុងនៅជាសិណាជនណា គេអោយរើសកំលាំង៨០នាក់ ហើយនារី៨០នាក់
យុវជន៨០នាក់ ដាក់ទៅ ហើយគេថាគេយកទៅវ៉ៃចោលផង
ហើយខ្ញុំអត់មានបានដឹងផង ខ្ញុំបានបើកក្រមាបើកអីអោយណា ក្រមាក្រហម
ហើយនឹងអាវខ្មៅនុងណា។បាទ កាលនុងខ្ញុំថាស្លាប់ហើយមើលទៅ
បើគេដាក់នារី៨០ ហើយយុវជន៨០នាក់។
កៈ កាលនុងដាក់ជិះឡានទៅហ៎?
ខៈបាទ! នៅកាលនុងជិះឡានទៅបាទ។ គេបើកនៅតាមខ្ទល់ជាតិហ្នឹង
គ្រាន់តែថាតានៅវត្តថ្មីខ្ទល់ណាចៅ។
កៈ ចឹងនៅខ្ទល់នុង?
ខៈ បាទ! នៅខ្ទល់នុង !
កៈ ហើយចឹងដល់ពេលតាបានទៅដល់នុងទៅ បានគេអោយ?
ខៈ ដល់នុងចឹងទៅបានសប្បាយចិត្តបានទៅដល់ចំការកៅស៊ូនុងណា។
កៈ ហឹម...។
ខៈ ហើយបាននៅក៏គេរករឿងចឹងគេសួរថាអ្នកឯងធ្វើអី ហើយបងប្អូននុងធ្វើអី
ម៉ាឪនុងធ្វើអី គេសួរថាចឹងណា! ហើយខ្ញុំក៏បានឆ្លើយប្រាប់គេវិញថា
ខ្ញុំនៅជាកម្មករបាទ ខ្ញុំអត់មានរាជការ អត់មានធ្វើពូលីស
អត់មាធ្វើជាទាហាននោះទេ ខ្ញុំប្រាប់គេថាចឹង តាមពិតបងប្អូនរបស់ខ្ញុំមាន
តែខ្ញុំបានប្រាប់ថាតែចឹង ដើម្បីអោយបានសុខ។
កៈ ចាស!
ខៈ វាឃើញងាប់ច្រើនគ្នា។
កៈ ចាស! ពេលនុងនៅក្នុង១ខែ គឺគេបានសួរមួយដងទៀត បាទ
គេសួរទៀតសួររហូត ទាល់តែដល់គ្រាប់ឆ្នាំ បានគេប្រែវិញហើយ បាទ!
ដល់ពេលប្រែវិញចឹងទៅ
គេបានដើរទៅសំឡឹងមើលមុខហើយណាអាទាហានៗពួកនុងអាប៉ុលពតនុង
វាមើលមុខ ហើយដល់ពេលយើងមើលមុខវាអានុងបានដៃវាហើយ
វាសំលាប់មនុស្សតែម្តងអាពតនុង។
កៈ មើលមុខអត់បាន!

ខៈ បាទ! ហើយដល់ពេលខ្ញុំនេះអត់មានហ៊ាននោះទេ! ខ្ញុំដាក់ចឹង
ខ្ញុំអង្គុយយកសុខចឹង ដល់ពេលបានអីចឹង
ក៏អង្គុយចឹងដែរអត់ហ៊ានមើលមុខវានោះទេ។
កៈ ចឹងនៅក្នុងរបបប៉ុលពតតាមានគ្រួសារ១ដែរ?
ខៈ បាទ! មានគ្រួសារមួយដែរ១។
កៈ ហ្នឹងអាពតរៀបអោយ?
ខៈ គេស៊ីរួចហើយបានជាអាពតគេអោយយើងហ៎!
កៈ ចឹង!
ខៈ ហ្នឹងតាប្រាប់ចឹង!
កៈ តែអាពតរៀបអោយនុងហេស?
ខៈ បាទ!គេរៀបអោយនុង!
កៈ រៀបនៅក្នុងអាពតនុងយ៉ាងម៉េចដែរតា?
ខៈ រៀបនុងទាល់តែបាន៤០គូបានគេរៀបអោយណាចៅ។
កៈ ចឹងនៅជំនាន់របស់តា៤០គូហ៎?
ខៈ បាទ៤០គូចៅ!
កៈ នៅក្នុងតែ១ថ្ងៃនោះទេ?
ខៈ ប្រហែលនុង!គេរៀប(២៤០:៤០)
កៈ ចាស?
ខៈ គេរៀបនៅទីកឆាយើង!
កៈ អូនៅកន្លែងទីកឆាយើងហ្នឹង?
ខៈ បាទនៅទីកឆានុងណា គេរៀបអោយនុងណាហើយរួចតាចេះតែនេះទៅ
ចេះតែអោយបានរួចម៉ាជីវិតសិន បើសិនជាយើងមិនយកនោះក៏ងាប់។
កៈ ចាស!
ខៈ បាទ!ម៉ាជំនាន់នុង ប៉ុន្តែគេស៊ីរួចអស់ហើយនារីៗហ៎ បាទ!
កៈ ហឹម...។
ខៈ តាប្រាប់ថាចឹង!
កៈ រួចទៅ គេអោយតាមានប្រពន្ធទៅតើប្រពន្ធរបស់តាមានឈ្មោះអ្វី?
ខៈ ឈ្មោះ កំព្រាន!
កៈ កំព្រាន!
ខៈ កំព្រានុងគេនៅខាងឯខេត្តសៀមរាបណ៎អាចៅ!
កៈ ឯសៀមរាបមកដល់ហ្នឹងណ៎!
ខៈ ហាក់! គេជំលាស់មកគ្រាប់កន្លែងណាចៅ!
កៈ ចឹងគ្រាប់ខេត្ត!
ខៈ បាទ! មកគ្រាប់ខេត្តគ្រាប់តំបន់ណាចៅ ម៉ាជំនាន់នុង
គឺគេបានមកឡើងគ្រាប់តំបន់ ហើយបុរសនុងទៅយកពួកខាងនុង បាទ
គេអោយ បើសិនជាយើងមិនយក ទោះបើជាខ្មៅក៏ដោយ សក៏ដោយ
យើងត្រូវតែយកបាទ គេអោយចឹង បើសិនជាងយើងមិនយកនោះត្រូវងាប់!
វាចឹង ងាប់ឡើងច្រើនគ្នាហើយ បានជាខ្ញុំថាយកក៏យកទៅ
អោយតែរួច១ពេលៗសិនទៅបាទ។
កៈ ដល់ពេលយកទៅក៏ គាត់នៅរស់ដល់សព្វថ្ងៃហ្នឹងទេ?
ខៈ ងាប់បាត់ហើយ! ងាប់បាត់ទៅហើយ។
កៈ អាពតយកទៅវៃចោល?
ខៈ បាទ! អាពតយកទៅវៃចោល វាលេងម៉ែឪរបស់វាស័ក៥ហើយដល់ពេលខ្ញុំ
រួចខ្លួន វាយកតែប្រពន្ធនោះទេ បាទស័ក៥។
កៈ អូ...។
ខៈ អត់ប្រាប់គេថាធ្វើស្រែធ្វើចំការចឹងទៅវាស្រួលទៅហើយ ។
កៈ ប្រាប់គេត្រង់!

ខះ នុងហើយ
ដល់ពេលប្រាប់គេត្រង់ចឹងទៅគេបានយកទៅវ៉ៃចោលឡើង១ភ្លាកទៅណា។
គេបានដាក់(២៦:១៤) វាចឹងណា
បានថាអាហ្នឹងហើយយើងមិនចេះនយោបាយណាចៅ។
កះ ចាសមិនចេះចូលស្ទឹងតាមបទ ចូលស្រុកតាមទេស។
ខះ បាទ! លេងចឹង ចង់ខ្ពស់ទៅជាងាប់ចៅ ចង់ខ្ពស់។
កះ ចាសរួចទៅគេអោយតាធ្វើអ្វីបន្តទៀតតា?
ខះ ធ្វើនុងទៅដល់កន្លែងនុង
គេអោយតានុងកាប់ដើមចេកនៅកន្លែងចុងភៅគេនុងណា
នៅកន្លែងដឹកជញ្ជូនឧបករណ៍គេនុងមានត្រីងៀតអីៗនុង
យកមកដាក់នៅក្នុងឃ្លាំងនុង មានលេខ២ លេខ១ចឹងណា ហើយតាមានលេខ១
ដែងភាពភានុងនៅលេខ២ ដល់រួចទៅ ដឹកជញ្ជូននោះគឺគោនោះទេ
រម៉ក់រទេះគោណា ដឹកមកទៅ ហើយដើមចេកអីចឹង មានត្រកួនក៏ដោយ
មានត្រឡាចក៏ដោយ មានល្ពៅក៏ដោយ
អ្នកស្រុកដូចថាមានប្រជាជនគេដាំចឹងទៅ ហើយបានទៅប៉េះមក
ហើយនៅខាងគេអ្នក
ចុងភៅនុងអោយគេស្លទៅ។បាយប៉ុននេះបានតែប៉ុណ្ណឹងនោះទេ
នៅក្នុង១នាក់បានតែប៉ុណ្ណឹងនោះទេ។
កះ ចឹងរបបនុងបានតែរបបក្នុង១នាក់បានតែមួយវែកស្វានុងនោះទេ?
ខះ ហ្នឹងហើយបានតែប៉ុណ្ណឹងនោះទេ
នេះអ្នកដែលគេជាអ្នកដឹកជញ្ជូនណា។ដូចថាបើសិនជាដូចជាចៅឯចឹង
ជាអ្នកចាក់ជ័រណា បាន២វែក ចឹង រួចក្រៅពីហ្នឹងមាន១អាទិត្យមានបង្អែម១ដង
មានចេកស្ងោរអីចឹងទៅ មានម្ហូរគ្រឿងអីចឹងទៅ មានស្លប្រហើរអីចឹងទៅ
ដល់ចឹងមានសុតតែទឹកចឹងទៅមិចៅ អត់មានបន្លែនោះទេ
បន្លែនោះគគោកតែវានោះមិនអោយដាក់នោះទេ បាទ
អោយយើងហ៊ុចតែទឹកនុង
ចឹងមានអីមកពីណាមានតែទឹកនុង។បាទហើយចឹងស្រាវាមានផឹកទៅ
ហើយយើងអត់មានចឹងអត់ហ៊ាននោះទេ ចៅ សុតតែគ្រឿងងាប់អារបស់នុង
ចឹងបានថាវេទនាណាតានោះ ម៉ាជំនាន់នុងបាទ
ហើយមកដល់ពេលសព្វថ្ងៃហ្នឹងទៀត តាចេះតែគស្ង៉ូរឿងថ្នាំហ្នឹងទៀត ចេះតែគស្ង៉ូ
ជួយសង្គ្រោះគេទៅបានបុណ្យ ហើយគេជាទៀត គេដឹងគុណតាទៀត
ថាតានុងចេះថ្នាំប៉ុណ្ណឹងហើយចេះជួយសង្គ្រោះគេអោយជាទៀត!
ទៅកន្លែងណាក៏មិនចេះសាបសូន្យនោះដែរចៅ តាប្រាប់ចៅចឹង។
កះ ចឹងតើមានមូលហេតុអ្វីបានជាតាបានទៅជួបដែលថា
ងាប់ដោយសារចង់កនុង?
ខះ អូ!... នុងតាអត់ដឹងដែរចៅ កាលទៅនុង
គឺទៅដោយសារការផ្សងព្រេននុងណាចៅ បាទផ្សងព្រេនតាមវាសនារបស់គេ
ហើយគេ ពេលគេទៅនុង គេទៅកាន់ធម៌គេបានទៅកាន់អាចឹងទៅ
គេជានារីណា
រួចខ្ញុំនេះមេម៉ាយម៉េនតែខ្ញុំមិនបានទៅមើលងាយមើលអីគេនោះទេ
ខ្ញុំជួយសង្គ្រោះគេខ្ញុំដើររកតែថ្នាំមួយមុខនោះទេ ខ្ញុំចេះតែជួយមើល
ខ្ញុំប្រាប់នៅថ្នាំមួយមុខនេះ ត្រូវរោគនេះ ខ្ញុំបានប្រាប់ចឹងណា
បើសិនជាចៅឯថាក្ដៅណា ឈឺក្បាលឈឺអីចឹងចៅឯយកមកបឺតមក
ហើយជាធម្មតាទៅមិនបាច់ដាំនោះទេ ហើយទៅជា។
កះ អូ!...
ខះ ចឹងបានវាចេះរាប់អានដល់ខ្ញុំ គេបានសុំខ្ញុំធ្វើជាឪពុក
មិចៅដែរងាប់ទៅនុងណា បានសុំធ្វើជាឪពុក។

កៈ ចាស!
ខៈ ហើយដល់ពេលខ្ញុំនេះវាអត់មានកូន
ក៏ខ្ញុំបានលឺគេសុំធ្វើជាឪពុកនោះគឺខ្ញុំអរណាស់ ខ្ញុំសំពះគេវិញ បាទ។
កៈ ចឹងតាមានទឹកចិត្តល្អណាស់!
ខៈ បាទ! ខ្ញុំស្មោះត្រង់ល្អណាស់ គឺម្ដាយឪថាគ្នាក្រមុំណា។
កៈ ចាស!
ខៈ ចឹងចេះទៅតាម! ចូលគេអ្នកធ្វើខាងកាន់យាយម៉ម ខាងយាយជីអីចឹងណា។
កៈ ចាស!
ខៈ ចឹងគេរកស៊ីចឹងទៅគេមិនបានរកស៊ីគេកាន់ធម៌ចឹង! បាទគេកាន់ធម៌។
កៈ ចឹងនាងនុងទៅរៀនធម៌ចឹង?
ខៈ បាទ! ទៅរៀនធម៌បានឃើញតែ២នោះទេ
មិនដឹងថានៅឯស្រុកណាអីឯណាបានឃើញតែចៅនុង២នោះទេបាទ
ឃើញតែប៉ុណ្ណឹងណាចៅស្រី។
កៈ ចាសហើយនាងនុងយ៉ាងម៉េចម៉ូលហេតុអ្វីបានជាគាត់ចឹង?
ខៈ វាដោយសារតែអាប្រុសនុងធ្វើបាបចិត្ត ដល់ពេលនេះទៅវាផើម ដល់ផើមទៅ
វាចាប់ធ្វើបាបរំលោបចឹងទៅ ក៏វារត់ទៅបាត់ទៅ
ដល់ពេលចឹងផើមអត់ហ៊ានចូលស្រុកខ្មាសគេចឹងហើយក៏សម្លាប់ខ្លួនឯង។បាទ
កៈ សម្លាប់នៅលើភ្នំ!
ខៈនៅលើភ្នំណាចៅ!
កៈនៅលើភ្នំឆាតនុង?
ខៈ បាទ! នៅលើភ្នំឆាតនុងណាចៅ ខាងជ្រោយភ្នំនៅគៀនភ្នំ ដល់ពេលទៅដល់
តាបានធ្វើបុណ្យធ្វើអីអោយ មានជញ្ជៀន មានក្រវិល សុខតែមាសទាំងអស់។
កៈ ចឹងមានគ្រឿងអល្លង្កាពាក់ដែរហ៎?
ខៈបាទ! មានទាំងអស់! បាទ! មានទាំងអស់របស់គេនុង។
កៈ ចាស ចឹងលក់គ្រឿងអល្លង្កានុងទៅយកទៅធ្វើបុណ្យអោយទៅ?
ខៈ បាទ យកទៅធ្វើបុណ្យអោយទៅនៅឯវត្តនុងទៅ ហៅចាស់ៗមកក៤ទៅ១០
ទៅ២០នាក់អីចឹងទៅណា បានជុំគ្នាហើយមានចំណីស្អីៗ ហើយលើខ្ញុំនេះទាំងអស់!
អស់ប៉ុន្មានខ្ញុំចេញតែម្ដង។
កៈ ចាស!
ខៈ បាទ! ខ្ញុំអត់មានចង់បានរបស់គេនោះទេ។
កៈ ចាចឹងដល់ពេលរយៈពេលប៉ុន្មានដែរបានជានាងនុង ប្រាប់ផ្ទាំតា?
ខៈ ប្រហែលជា៣ថ្ងៃបានមកប្រាប់តែម្ដង បាទ ។
កៈតើមកប្រាប់នុងតើមកប្រាប់យ៉ាងម៉េច?
ខៈ ឃើញមកស្ទុយមក ហោះមកតែម្ដងណាចៅ មកត្រឹមហ្នឹងណាចៅ
អត់មានឃើញជើង មកត្រឹមចង្កេះហ្នឹង អត់មានឃើញជើងនោះទេ
ឃើញដៃនៅត្រឹមហ្នឹងធ្វើចឹង ធ្វើដូចចឹងបាទ ដៃណា
ហោះមកស្រាប់តែប្រាប់តាថាៈ
តាថ្នាំនេះ១ជួយខ្ញុំអោយបានដល់ឃើញធ្វើបុណ្យមាសរបស់ខ្ញុំ
បានតាឯងនុងជួយខ្ញុំ ឥឡូវខ្ញុំសងគុណតាឯងវិញបាទ
សងគុណអោយទៅកាប់ថ្នាំនេះមួយថ្នាំនោះ១ រោគនេះត្រូវហ្នឹងរោគអីខ្ញុំប្រាប់
បើសិនជាតាឯងមិនជឿនោះតាឯងទៅមើល
ទៅមើលស្លឹកឈើនោះតាឯងដឹងហើយ! ដល់ចឹងម៉ែនខ្ញុំទៅស៊ីមែន ។
កៈ ចាស!
ខៈ ដល់ពេលស៊ីទៅវាត្រជាក់ ហើយដល់ពេលស៊ី១ទៀតទៅក៏វាត្រជាក់
ហើយអាវិលនុងដាកក់ទៅបាត់វិល ហ្នឹងដល់ពេលឃើញចឹងនាងនុងប្រាប់ថា
បានខ្ញុំកត់ ១សៀវភៅនុងកត់ទុកតែម្ដង។

កៈ ចឹងដល់ពេលតាឃើញនាងខ្ញុំមកឃើញនាងនុងនៅក្នុងយល់សព( សុបិន្ត)?
ខៈ អត់មានយល់សពនោះទេ ឃើញដូចជានាងឯងចឹង បាទដូចរស់ចឹង ឃើញរូបរស់តែម្តងណាចៅ។
កៈ រួចតានៅពេលនុងតើតាមានអារម្មណ៍យ៉ាងម៉េចដែរ?
ខៈ អត់មានខ្លាចបើសិនជាតាមានព្រះរបស់តា តាមានប្រដាប់របស់តាទាំងអស់ តាដាក់មកទាំងអស់។
កៈចឹងដល់ពេលតាបានទៅភ្នំនុងដូចថាគេហៅថាដំឡូងមូល?(អត់មានអីការពារខ្លួន)
ខៈ អត់ទេ! មានទាំងអស់! មានតាំងពីស្ពឺគេក៏មាន មានតាំងពីចែលមានតាំងពីអីប្រដាប់ទាំងអស់ ដាក់ខ្លួនតា សាលិកាលន់ផោងអី តានៅជាមួយនឹងសាំសារុន។
កៈ តានៅជាមួយនឹងសាំសារុនហ្នឹង?
ខៈ បាទ! ចៅឯស្គាល់ដែរឬទេសាំសារុនហ្នឹង?
កៈ ស្គាល់តើ តួល្ខោនកាលពីដើម។
ខៈ ហ្នឹងហើយ!ក៏ប៉ុន្តែតាអត់ចេះច្រើន បើសិនជាតាចេះច្រៀងវិញដូចគ្នា សាំសារុនហើយនិងខ្ញុំហ្នឹងគឺដូចគ្នា។ ចឹងកំលាំងកំពារអីដូចគ្នា ខ្ញុំដាក់សាលិកាលន់ថោនសាំសារុនចាក់អោយខ្ញុំ ។
កៈ ចាស!
ខៈ ហើយនេះកូនព្រះ មានញីមានឈ្មោល សារិកាលន់ថោនចឹងហើយបានជាតាចេះតែលក់ទៅដាច់ចឹងនោះ ហើយចឹងទៅថ្នាំហ្នឹងក៏សាំសារុនក៏ប្រាប់២ទៅ៣ម៉ាត់ដែរបាទ ថ្នាំវិលដែរ។
កៈចឹងតាសាំសារុនកាលពីដើមនោះក៏បានប្រាប់ថ្នាំដល់តាដែរហ៎?
ខៈ គាត់ក៏បានប្រាប់ដែរ គាត់មិនអោយភ្លេចបុណ្យរបស់គាត់នោះទេ។
កៈចាស!
ខៈ ហើយគាត់ណា តាប្រាប់ចៅ តាំងពីកាំបិតរបស់គាត់ឡើង។
កៈចាស!
ខៈ ចឹងនេះ ! នេះកាំបិតរបស់កាត់ គាត់បានទុកអោយ គាត់បានប្រាប់ថាដល់ពេលទៅដល់ទីណាគឺអោយដាច់ដូចសេចក្តីប្រាថ្នា គាត់និយាយចឹង ចឹងទៅដល់កន្លែងណាក៏ដោយសុំតែសុខ ។
កៈ ចាស!
ខៈ ចឹងគាត់ទាំងអស់ គឺសុំតែសុខ។
កៈ
ចឹងព្រះអង្គតា២ព្រះនុងយ៉ាងម៉េចដែរតានិយាយអំពីប្រវត្តិរបស់ព្រះអង្គនុងទៅមើល?
ខៈ ព្រះអង្គនុងតាប្រាប់ត្រង់ណាចៅស្រី តាប្រាប់អំពីព្រះអង្គតានុងមានតែ២នោះទេ នេះនៅលើភ្នំសន្ទុកណា។
កៈ ចឹងព្រះអង្គឈើនុង១ព្រះអង្គនៅលើភ្នំសន្ទុក ហើយ១អង្គនេះនៅលើភ្នំឆាតណាចៅស្រីណា។
កៈ ចាសហើយទៅព្រះអង្គកែវនេះនៅលើភ្នំឆាត។
ខៈ បាទនៅលើភ្នំឆាតនោះទេណាចៅស្រីអឺម!។
កៈ ចឹងព្រះអង្គកែវហ្នឹង តើតាយកបាននៅក្នុងឆ្នាំណា?
ខៈ នៅនឹងឈើ!
កៈ នៅនឹងមែកឬក៏គល់?
ខៈ នៅនឹងមែកណាចៅ !
កៈ ចឹងឃើញនៅនឹងគល់?
ខៈ បាទ! ជ្រូកវាជួយប្រាប់!
កៈ ជ្រូកអី?

ខ៖ជ្រូកព្រៃណាវាជួយប្រាប់ វាឆ្មួសអោយ ដល់ចឹងចេញមករូបព្រះអង្គ។
ក៖ នៅភ្នំឆាតហ្នឹង?
ខ៖ បាទ! នៅលើភ្នំឆាតនុង នៅអែបនឹងភ្នំយើងតែម្តង។
ក៖ ចុះភ្នំឆាតនុងនៅឯណាដែរតា?
ខ៖ នៅអែបនឹងយើងដែរ!
ក៖ នៅខេត្តកំពង់ធំនុង? នៅលើខេត្តកំពង់ចាម?
ខ៖ មិនមែននៅក្នុងខេត្តកំពង់ចាមនោះទេ នៅក្នុងខេត្តអី!...
ក៖ រតនៈគីរីនុង?
ខ៖ បាទ! នុងហើយនៅក្នុង នុងហើយមិនមែននៅខេត្តនេះនោះទេ!
ក៖ ចឹងភ្នំឆាតនុងនៅក្នុងខេត្តរតនៈគីរីនុងហ៎?
ខ៖ បាទ!នុងហើយនៅក្នុងខេត្តរតនៈគីរីនោះទេចៅ។
ក៖ អូ! ចឹងតាមានបានចាំដែរឬទេថាបានរូបព្រះអង្គហ្នឹងមកនៅក្នុងឆ្នាំណា?
ខ៖ ឆ្នាំពីរពាន់! អាហ្នឹងបើសិនជានិយាយអោយចំនោះមើល!...កាលតាទៅនុង ២០១៨។
ក៖ ចឹងទើបតែបាន១ឆ្នាំហ្នឹងចឹង?
ខ៖ អត់នោះទេ ២០១៨ និង២០១៩ ហេស!! មិនមែននោះទេ។
ក៖ ឥឡូវនេះ២០១៩ហើយតាចឹងនៅឆ្នាំ២០០៨អីនោះទេហេស?
ខ៖ ហេស! ឆ្នាំ២០០៧ តាទៅនុង។
ក៖ ២០០៧!
ខ៖ បាទ! ២០០៧តាចេញទៅនុងហ៎!
ក៖ ចឹងបានជាង១០ហើយ!
ខ៖ បាទ! នៅឆ្នាំ២០០៧តាបានទៅនុងហ៎!
ក៖ ចាសចឹងបានជាង១០ហើយតា! ហើយបានព្រះអង្គនុងមកដូចថាតាចេះតែ...
ខ៖ ដើរប្រោះសត្វលោក!
ក៖ លក់ថ្នាំហ្នឹងហ៎?
ខ៖ បាទ!ជួយសង្គ្រោះមនុស្សលោក តែថាទឹកនៅចឹងណា ។
ក៖ ចាស!
ខ៖ ដាក់ទឹកចឹងទៅត្រជាក់តែម្តងណាចៅ! គឺត្រជាក់តែម្តង
ហើយបើសិនជាប្រាប់លេខឆោតនោះគឺព្រះអង្គនុងបានចេញហើយ
បើសិនជាចៅឯចេះមើលឃើញ! អាហ្នឹងបើសិនជាអ្នកមាននិស្ស័យបានមើលឃើញ
តែបើសិនជាអ្នកគ្មាននិស្ស័យនោះមើលអត់ឃើញនោះទេចៅ។នេះតាប្រាប់ចឹង
អោយដឹងបាទ!
ក៖ ចាស! ចឹងព្រះអង្គនេះនៅភ្នំសន្ទុក!
ខ៖ សំរាប់ព្រះអង្គនេះ គឺជួយថាមកសន្និតមករូបខ្ញុំដែរ
ដូចថាអោយខ្ញុំមានអារម្មណ៍ថាមានអាស្រ័យអន់ក្រ ព្រះអង្គជួយទាំង២ហ្នឹង។
ក៖ ទាំង២ហ្នឹង?
ខ៖ បាទ!ទាំង២ហ្នឹងបានជួយទាំងអស់ មើលឃើញចឹង
បើសិនជាតែញ៉ាក់ភ្នែកកុំទៅព្រះអង្គប្រាប់ចឹង។
ក៖ ចឹងហ៎!
ខ៖ បាទ!
ក៖ ចឹងព្រះអង្គនៅភ្នំសន្ទុកនេះ បានមកយ៉ាងម៉េចដែរ?
ខ៖ បានមកនៅវាត្រជាក់ត្រជុំ!
ក៖ មុននឹងបាននៅតើគេបានអោយតាទៅឃើញនៅកន្លែងណា?
ខ៖ មុននឹងបាននុងស្រីក្រមុំ បាទ! ស្រីក្រមុំ!បាទ។
ក៖ ប្រាប់តាយ៉ាងម៉េចដែរ?
ខ៖ ប្រាប់ថា!៖ តាឯងបើសិនជាទៅយកព្រះអង្គឈើនុង ខ្មៅនុង
គឺតាឯងទៅឯណាមានសំណាងហើយ

គឺគេអោយតាឯងបានដឹងហើយបានចេះដំរិះតាឯង ហើយបានលុយមកឆាប់ៗ ព្រះអង្គទាំង២ហ្នឹង ប្រាប់ថាចឹងណា។
ក៖ ចាស!
ខ៖ បាទ! ហើយបើសិនជាមិនចឹងតាឯងទាយអត់ត្រូវនោះទេ អត់មានព្រះអង្គ២ហ្នឹងហាំ ហ្នឹងគេថាខ្មោចកាន់ស្លាប់បានដែរឬទេ ខ្មោចបីសាចព្រាយនៅកន្លែងនុងគេកាន់ ព្រះអង្គនុងណា។
ក៖ ចង់និយាយថាតាទាយគេទៅអត់ត្រូវយ៉ាងម៉េច?
ខ៖ បើសិនជាមិនត្រូវអត់យកលុយ!
ក៖ អូ!...
ខ៖ បាទ! និយាយចេស ណាចៅ!
ក៖ ចឹងបានព្រះអង្គនុងមក! បានព្រះអង្គហ្នឹងជួយ!
ខ៖ បាទ! ព្រះអង្គជួយ! បាទៗ
ក៖ គឺបានជួយអោយផ្សំថ្នាំអីចឹង!
ខ៖ បាទ! បើសិនជានិយាយនោះវិញដូចជានិយាយទូរសព្ទចឹងណាចៅ ។
ក៖ ចឹងពេលមើលទៅជាៗ?
ខ៖ និយាយទៅមើលលើទឹកដីហ្នឹង ចៅឯងរកមិនបានអីមិនបាននុងរកព្រះអង្គ២ហ្នឹងទៅ ហើយទៅមានធូក មានលុយកាកអីចឹង១០០០ក៏ដោយ ៥០០០អីចឹងទៅ អោយមានទឹកអប់អីមកដាក់ស្រោចចឹងឃើញហើយ! ឃើញទៅចៅឯងហើយ នេះតាប្រាប់អោយច្បាស់ចឹង។
ក៖ សាមីខ្លួននុងឃើញផ្ទាល់តែម្តងឬក៏តាឃើញតានិយាយប្រាប់ចៅ?
ខ៖ បាទ! ប្រាប់ចឹងតែម្តងចៅ! ប្រាប់ចឹងទៅឃើញតែម្តង ថាចៅឯងនៅថ្ងៃនេះកុំទៅ មានគ្រោះថ្នាក់! តាប្រាប់ថាចឹងណា ។
ក៖ ចាស!
ខ៖ បើសិនជាទៅ អោយមានអុជធូកនៅកន្លែងកុងមា ហ្នឹង៣សរសៃទៅ អុជនៅនឹងកុងមានុង ពេលដើរទៅណាគឺសុខរហូតហើយចៅឯង។
ក៖ អូ!...
ខ៖ បាទ!ប្រាប់ប៉ុណ្ណឹងចៅ!
ក៖ តាចឹងមុនហ្នឹងបញ្ចប់តាមានពាក្យពេចន៍អ្វីដើម្បីផ្តាំផ្ញើដល់កូនចៅ និងកូនជំនាន់ក្រោយទៀត តាអត់មានកូននោះទេ ក៏ប៉ុន្តែ...
ខ៖ បាទ!
ក៖ ហើយតាអត់មានចៅទៀត! ចឹងតាមានតែប្អូនៗជំនាន់ក្រោយនេះណា!
ខ៖ បាទៗ អោយចៅឯងទៅ ដូចអោយដូចតាណាចៅណា! អោយរកស៊ីទៀងត្រង់ អោយអាយុវែង អោយទៅកន្លែងណាគឺសុំតែសុខនៅកន្លែងនៅ ដូចរបស់តាចឹង តាមានតែព្រះអង្គ២ហ្នឹង មានព្រះកែវ មានដែងនៅលើក្នុំសន្ទូកចឹងណា អោយចៅឯងអោយមានសំណាងទៅកន្លែងណាអោយសុខសប្បាយ អោយចៅឯងចេះរកអោយមានកប់ដូចសេចក្តីប្រាថ្នាដូចចៅឯង។
ក៖ ចាស!កុំអោយគេមកបៀតបៀន អីចឹងសូមអោយគេជៀសអោយឆ្ងាយចឹងទៅណា?
ខ៖ ហ្នឹងហើយ! ហ្នឹងណាបានហើយចៅ!
ក៖ ចឹងខ្ញុំសូមអឹម...អរគុណតាច្រើនដែរលះបង់ពេលវេលាមានតំលៃអនុញ្ញាតអោយ ចៅធ្វើការសម្ភាសដឹងអំពីជីវៈប្រវត្តិដឹងអំពីក្រុមគ្រួសាររបស់តា ហើយខ្ញុំសូមជូនពរតា អោយតាជួបតែពរ៤ប្រការ គឺអាយុវណ្ណៈសុខៈពាលៈ កុំប្បីឃ្លានឃ្លាតឡើយ។
ខ៖ បាទ!
ក៖ អរគុណច្រើនជំរាបលាណាតា!

ខ៖ បាទអរគុណចៅសុខសប្បាយចៅ!៕